01589560

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Preliminaire

**D360/7**

តាមនាមប្រជារាស្ត្រខ្មែរ និងតាមនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពី
ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម
ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០៤/២/០៧-០៩-២០០៩-អវតក/កសចស

ចំពោះមុខ: ចៅក្រម ប្រាក់ គីមសាន ជាប្រធាន
ចៅក្រម Olivier BEAUVALLET
ចៅក្រម ន៉ី ថុល
ចៅក្រម Kang Jin BAIK
ចៅក្រម ហួត វុទ្ធី

កាលបរិច្ឆេទ: ថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៨

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 08 / 11 / 2018
ម៉ោង (Time/Heure): 11:40
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

---

សាធារណៈ:កោសលុប

**សេចក្តីសម្រេចលើសំណើសុំបន្ថែមពេលវេលា និងចំនួនទំព័រកំណត់ សម្រាប់បណ្តឹងឧទ្ធរណ៍**
**របស់ [redacted] លើដីកាដំណោះស្រាយ (បញ្ជូនរឿងទៅជំនុំជម្រះ)**

---

**សហព្រះរាជអាជ្ញា:**

ជា លាង
Nicholas KOUMJIAN

**សហមេធាវីការពារក្តី [redacted]:**

មុំ លុជ្ឈ
Richard ROGERS
Göran SLUITER

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ជេត វណ្ណលី
ហុង គីមសួន
គីម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន សុវ៉ន
ទី ស្រីនណា
វ៉ែន ពៅ

Laure DESFORGES
Isabelle DURAND
Emmanuel JACOMY
Martine JACQUIN
Daniel MCLAUGHLIN
Nushin SARKARATI

**អង្គបុរេជំនុំជម្រះ**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") បានទទួល "សំណើសុំបន្ថែមពេលវេលា និងចំនួនទំព័រកំណត់សម្រាប់បណ្តឹងឧទ្ធរណ៍របស់ [redacted] លើដីកាដំណោះស្រាយ (បញ្ជូនរឿងទៅជំនុំជម្រះ)" ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៨ ("សំណើ")[1]។

1. នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ សហចៅក្រមស៊ើបអង្កេតជាតិបានចេញ "ដីកាដំណោះស្រាយ" របស់ខ្លួន[2] ជាភាសាខ្មែរ ដោយលើកលែងការចោទប្រកាន់ទៅលើ [redacted] ចំណែកសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចេញ "ដីកាដំណោះស្រាយ (បញ្ជូនរឿងទៅជំនុំជម្រះ)" របស់ខ្លួន[3] ជាភាសាអង់គ្លេស។ នៅថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៨ អង្គបុរេជំនុំជម្រះបានបង្គាប់ឱ្យភាគីដាក់សេចក្តីជូនដំណឹងពីបណ្តឹងឧទ្ធរណ៍ក្នុងរយៈពេល ១៤ ថ្ងៃ ចាប់ពីថ្ងៃទទួលការជូនដំណឹងពីការបកប្រែភាសានៃដីកាដំណោះស្រាយទាំងពីរ[4]។ នៅថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៨ សហមេធាវីការពារក្តី អោ អាន ("សហមេធាវី") បានដាក់ការជូនដំណឹងពីបណ្តឹងឧទ្ធរណ៍លើដីកាដំណោះស្រាយ (បញ្ជូនរឿងទៅជំនុំជម្រះ) របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ[5]។ ការបកប្រែភាសានៃដីកាដំណោះស្រាយត្រូវបានជូនដំណឹងនៅថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨ និងថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៨។

---

[1] សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស ("សំណុំរឿង ០០៤/២") សំណើសុំបន្ថែមពេលវេលា និងចំនួនទំព័រកំណត់សម្រាប់បណ្តឹងឧទ្ធរណ៍លើដីកាដំណោះស្រាយ (បញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៨ ឯកសារ D360/4 ("សំណើ")។

[2] សំណុំរឿង ០០៤/២ ដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងការចោទប្រកាន់) ចេញថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ ជាភាសាខ្មែរតែមួយភាសា ឯកសារ D359។

[3] សំណុំរឿង ០០៤/២ ដីកាដំណោះស្រាយ (បញ្ជូនរឿងទៅជំនុំជម្រះ) ចេញថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ ជាភាសាអង់គ្លេសតែមួយភាសា ឯកសារ D360។

[4] សំណុំរឿង ០០៤/២ ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំបន្ថែមពេលវេលាកំណត់សម្រាប់សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ ចុះថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១៨ ឯកសារលេខ D359/2 សូមមើលផងដែរ សំណុំរឿង ០០៤/២ សំណើរបស់សហព្រះរាជអាជ្ញាសុំបន្ថែមពេលវេលាកំណត់សម្រាប់សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៨ ឯកសារ D359/1។

[5] សំណុំរឿង ០០៤/២ ការជូនដំណឹងអំពីការប្តឹងឧទ្ធរណ៍លើដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៨ ឯកសារ D360/5។

2. នៅថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៨ សហមេធាវីការពារក្តី [redacted] បានដាក់សំណើ។ សហព្រះរាជអាជ្ញាបានដាក់ចម្លើយតបនៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៨[6] ហើយសហមេធាវីមិនបានធ្វើការឆ្លើយតបទេ។

3. សហមេធាវីស្នើសុំបន្ថែមពេលវេលាកំណត់សម្រាប់ដាក់បណ្តឹងឧទ្ធរណ៍របស់ [redacted] ពី ៣០ ថ្ងៃ ទៅដល់ ១២០ ថ្ងៃ និងចំនួនទំព័រកំណត់ពី ៣០ ទំព័រ ទៅដល់ ៣០០ ទំព័រ[7]។ ពួកគេបានស្នើថែមទៀតដល់អង្គជំនុំជម្រះសុំអនុញ្ញាតឲ្យពួកគេដាក់បណ្តឹងឧទ្ធរណ៍ជាភាសាអង់គ្លេសជាមុនសិន ហើយថា ពេលវេលាសម្រាប់ដាក់បណ្តឹងឧទ្ធរណ៍ និងចម្លើយតប គួរចាប់ផ្តើមគិតពីថ្ងៃចេញដីកាដំណោះស្រាយ និងពីពេលដាក់បណ្តឹងឧទ្ធរណ៍ទាំងអស់យ៉ាងហោចណាស់មួយភាសា[8]។ ពួកគេលើកឡើងថា សំណើសុំបន្ថែមពេលវេលាស្របទៅនឹងការអនុវត្តន៍កន្លងមកនៅ អ.វ.ត.ក និងនៅតុលាការអន្តរជាតិផ្សេងទៀត ហើយថា វាជាការចាំបាច់ ដើម្បីការពារសិទ្ធិជាសារវន្តរបស់ [redacted] ក្នុងការទទួលបានការការពារក្តីយ៉ាងមានប្រសិទ្ធភាព[9]។ ពួកគេសំអាងទៅលើអត្ថិភាពនៃកាលៈទេសៈពិសេសដូចជា ការចេញដីកាដំណោះស្រាយពីរដាច់ពីគ្នា និងផ្ទុយខ្លឹមសារគ្នា ដែលអាចមានបណ្តឹងឧទ្ធរណ៍បកវិញ[10] ដីកាដំណោះស្រាយទាំងពីរវែង និងស្មុគស្មាញ[11] ចំនួនទឡ្ហីករណ៍ដែលបានព្យាករណ៍សម្រាប់បណ្តឹងឧទ្ធរណ៍នេះ[12] ព្រមទាំងការចេញសាលក្រមនៅក្នុងសំណុំរឿង ០០២/០២[13]។

---

[6] សំណុំរឿង ០០៤/២ ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងសំណើរបស់ [redacted] ស្នើសុំបន្ថែមពេលវេលា និងចំនួនទំព័រកំណត់សម្រាប់បណ្តឹងឧទ្ធរណ៍របស់គាត់ប្រឆាំងនឹងដីកាដំណោះស្រាយ (បញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ ២០១៨ ឯកសារ D360/6 ("ចម្លើយតប")។

[7] សំណើ កថាខណ្ឌ ៤, ១៧-១៨, ៣៩។

[8] សំណើ កថាខណ្ឌ ៤, ១៩-២០, ៣៩។

[9] សំណើ កថាខណ្ឌ ៦, ២២, ៣១-៣៥, ៣៧។

[10] សំណើ កថាខណ្ឌ ៥, ២៣, ៣៨។

[11] សំណើ កថាខណ្ឌ ៥, ២៤-២៦។

[12] សំណើ កថាខណ្ឌ ៥, ២៧-២៨។

[13] សំណើ កថាខណ្ឌ ៥, ២៩-៣០។

4. សហព្រះរាជអាជ្ញាបានឆ្លើយតបថា សំណើសុំបន្ថែមពេលវេលា និងចំនួនទំព័រ ជាចំនួនច្រើនហួសហេតុពេកដែលធ្វើឲ្យមានការពន្យារពេលមិនសមរម្យ[14] ហើយថា អង្គជំនុំជម្រះគួរផ្តល់ការបន្ថែមពេលវេលា និងចំនួនទំព័រខ្លីជាងនេះស្មើៗគ្នាដល់ភាគីទាំងអស់ ហើយអនុញ្ញាតឲ្យដាក់បណ្តឹងឧទ្ធរណ៍មួយភាសា ចំណែកពេលវេលាគឺចាប់ផ្តើមគិតពីការបកប្រែភាសានៃដីកាដំណោះស្រាយទាំងពីរ[15]។ ពួកគេរម្លឹកថា ទំហំនៃការពន្យារពេល និងបន្ថែមចំនួនទំព័រដែលអង្គជំនុំជម្រះបានអនុញ្ញាតពីមុន គឺតូចជាងសំណើសុំរបស់ [redacted] នៅពេលនេះ ហើយលើកឡើងថា បណ្តឹងឧទ្ធរណ៍លើដីកាបញ្ជូនរឿងទៅជំនុំជម្រះមិនអាចប្រៀបធៀបជាមួយបណ្តឹងសាទុក្ខលើសាលក្រមអង្គសេចក្តីបានទេ[16]។ សហព្រះរាជអាជ្ញាអន្តរជាតិរំពឹងទុកថា គាត់នឹងត្រូវការចំនួនពី ៥០ ទៅ ៧៥ ទំព័រ និងបន្ថែមពេលវេលារហូតដល់ ៦០ ថ្ងៃ សម្រាប់បណ្តឹងឧទ្ធរណ៍របស់គាត់ ចំណែកសហព្រះរាជអាជ្ញាជាតិនឹងប្រកាន់យកពេលវេលា ៣០ ថ្ងៃ និងចំនួន ៣០ ទំព័រដែលបានកំណត់[17]។ ចុងក្រោយសហព្រះរាជអាជ្ញាទាំងពីរជំទាស់ទៅនឹងសំណើសុំការសម្រេចថា ពេលវេលាកំណត់សម្រាប់ចម្លើយតបត្រូវចាប់ផ្តើមគិតពីពេលដាក់បណ្តឹងឧទ្ធរណ៍យ៉ាងហោចណាស់មួយភាសា[18]។

5. អនុលោមតាមវិធាន ៣៩(២) និង(៤) នៃវិធានផ្ទៃក្នុង អង្គបុរេជំនុំជម្រះអាចកំណត់ និង/ឬ ពន្យារពេលកំណត់សម្រាប់ដាក់ឯកសារពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍។ ផ្អែកលើមាត្រា ៥(៤) នៃសេចក្តីណែនាំអនុវត្តន៍ស្តីពីការដាក់ឯកសារ ក្នុងកាលៈទេសៈពិសេស អង្គជំនុំជម្រះក៏អាចបន្ថែមទំព័រកំណត់ចំពោះឯកសារបានដែរ។

6. នៅក្នុងករណីនេះ ដោយសារមានដីកាដំណោះស្រាយចំនួនពីរដាច់ពីគ្នា ហើយអាចមានបណ្តឹងឧទ្ធរណ៍បកវិញ អង្គបុរេជំនុំជម្រះយល់ឃើញថា ការអនុញ្ញាតឲ្យភាគីទាំងអស់បន្ថែមពេលវេលាកំណត់ និងចំនួនទំព័រសម្រាប់ដាក់បណ្តឹងឧទ្ធរណ៍របស់ខ្លួន ជាការសមហេតុសមផល។ ក៏ប៉ុន្តែ

---

[14] ចម្លើយតប កថាខណ្ឌ ៨, ១៥។

[15] ចម្លើយតប កថាខណ្ឌ ១៧, ១៩-២០។

[16] ចម្លើយតប កថាខណ្ឌ ៩-១៤។

[17] ចម្លើយតប កថាខណ្ឌ ១៥-១៦។

[18] ចម្លើយតប កថាខណ្ឌ ១៨, ២០។

អង្គជំនុំជម្រះមិនជឿថា ដីកាដំណោះស្រាយ និងបណ្ដឹងឧទ្ធរណ៍ដែលរំពឹងទុកមានភាពស្មុគស្មាញរហូតដល់សហមេធាវីត្រូវការចំនួនទំព័រ ១០ ដង ឬពេលវេលាបន្ថែមចំនួន ៩០ ថ្ងៃទៀត ដើម្បីរៀបចំសេចក្ដីសន្និដ្ឋានរបស់ខ្លួនលើបណ្ដឹងឧទ្ធរណ៍នោះឡើយ។ អង្គជំនុំជម្រះក៏យល់ឃើញផងដែរថា ការចេញសាលក្រមនៃសំណុំរឿង ០០២/០២ មិនមានផលប៉ះពាល់ទៅលើបណ្ដឹងឧទ្ធរណ៍លើដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ នោះដែរ។ ហេតុនេះ អង្គជំនុំជម្រះសន្និដ្ឋានថា ដើម្បីជាប្រយោជន៍យុត្តិធម៌ និងដើម្បីឲ្យមានតុល្យភាពរវាងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងប្រសិទ្ធផលនោះ ជាការសមរម្យដែលអនុញ្ញាតឱ្យភាគីទាំងអស់បន្ថែមចំនួន ៧០ ទំព័រថែមទៀត និងបន្ថែមពេលវេលាចំនួន ១៥ ថ្ងៃថែមទៀត ចាប់ពីថ្ងៃទទួលការជូនដំណឹងពីការបកប្រែភាសានៃដីកាដំណោះស្រាយទាំងពីរនៅថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៨។

**អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆន្ទ៖**

**ទទួលយកតាម**សំណើមួយផ្នែក។

**អនុញ្ញាតឲ្យ**ភាគីដាក់បណ្ដឹងឧទ្ធរណ៍លើដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ ក្នុងរយៈពេល ៤៥ ថ្ងៃ ចាប់ពីថ្ងៃទទួលការជូនដំណឹងពីការបកប្រែភាសានៃដីកាដំណោះស្រាយទាំងពីរ។

**អនុញ្ញាតឲ្យ**ភាគីដាក់សេចក្ដីសន្និដ្ឋានលើបណ្ដឹងឧទ្ធរណ៍ចំនួន ១០០ ទំព័រ។

**អនុញ្ញាតឲ្យ**ភាគីដាក់បណ្ដឹងឧទ្ធរណ៍របស់ខ្លួនជាភាសាមួយសិន ចំណែកសំណើបកប្រែភាសានឹងដាក់នៅពេលក្រោយ។

**ណែនាំឲ្យ**អង្គភាពបកប្រែភាសាផ្ដល់ការធានាថា ការបកប្រែភាសាដែលដាក់ស្នើនឹងត្រូវចេញក្នុងរយៈពេល ៣០ ថ្ងៃ ចាប់ពីពេលដាក់បណ្ដឹងឧទ្ធរណ៍។

**ជូនដំណឹង**ថា សេចក្ដីណែនាំនានាពាក់ព័ន្ធនឹងការដាក់ចម្លើយតប និងការឆ្លើយតបនឹងចេញនៅក្នុងពេលវេលាសមស្រប។

**បដិសេធ**ផ្នែកផ្សេងទៀតនៃសំណើ។

អនុលោមតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង សេចក្តីសម្រេចនេះបិទផ្លូវតវ៉ា។

**រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៨**

**អង្គបុរេជំនុំជម្រះ**

**ប្រធាន**

**ប្រាក់ គឹមសាន** **Olivier BEAUVALLET** **ន៉ី ធុល** **Kang Jin BAIK** **ហួត វុទ្ធី**